# សន្ធិសញ្ញា
# ស្តីពី
# នីតិវិធីជំនួយផ្នែកច្បាប់
# ឱ្យគ្នាទៅវិញទៅមកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ

# មាតិកា


| | |
|---|---|
| មាត្រា ១ | វិសាលភាពនៃជំនួយ |
| មាត្រា ២ | ការមិនអនុវត្ត |
| មាត្រា ៣ | ការកំរិតលើជំនួយ |
| មាត្រា ៤ | ការតែងតាំងអាជ្ញាធរកណ្តាល |
| មាត្រា ៥ | ទម្រង់សំណើ |
| មាត្រា ៦ | ខ្លឹមសារសំណើ |
| មាត្រា ៧ | ការអនុវត្តន៍សំណើ |
| មាត្រា ៨ | ការកំរិតលើការប្រើប្រាស់ភស្តុតាងដែលទទួលបាន |
| មាត្រា ៩ | ការរក្សាការសំងាត់ |
| មាត្រា ១០ | ការទទួលយកកំណត់ហេតុដោយស្ម័គ្រចិត្ត |
| មាត្រា ១១ | ការទទួលយកភស្តុតាង |
| មាត្រា ១២ | សិទ្ធិ បដិសេធន៍ក្នុងការផ្តល់ភស្តុតាង |
| មាត្រា ១៣ | ការផ្តល់ឯកសារ និងរបាយការណ៍ផ្សេងៗ ដែលមានជាសាធារណៈ (ចំហ) |
| មាត្រា ១៤ | ការចូលរួមរបស់បុគ្គលនៅក្នុងភាគីម្ចាស់សំណើ |
| មាត្រា ១៥ | ការចូលរួមរបស់បុគ្គលដែលស្ថិតក្នុងការ ឃុំខ្លួននៅក្នុងភាគី ម្ចាស់សំណើ |
| មាត្រា ១៦ | លិខិតបើកផ្លូវ |
| មាត្រា១៧ | ការបញ្ជូនមនុស្សកំពុងជាប់ឃុំ |
| មាត្រា១៨ | ការឆែកឆេរ និង ការដកហូត |
| មាត្រា១៩ | ការបញ្ជូនភស្តុតាងត្រឡប់ទៅវិញ |
| មាត្រា២០ | ទីតាំង និង អត្តសញ្ញាណរបស់បុគ្គល |
| មាត្រា២១ | សេវាឯកសារ |

| | |
|---|---|
| មាត្រា២២ | ជំនួយនៅក្នុងចំណាត់ការរឹបអូស |
| មាត្រា២៣ | ភាពចុះសំរុង ជាមួយនឹងការរៀបចំ |
| មាត្រា២៤ | វិញ្ញាបនកម្ម និង ភស្តុតាងបញ្ជាក់ |
| មាត្រា២៥ | ថ្លៃចំណាយ |
| មាត្រា២៦ | ការពិគ្រោះយោបល់ |
| មាត្រា២៧ | វិសោធនកម្ម |
| មាត្រា២៨ | ដំណោះស្រាយវិវាទ |
| មាត្រា២៩ | ខរក្សាសិទ្ធិ |
| មាត្រា៣០ | ហត្ថលេខា សច្ចាប័ន ការការចូលជាសមាជិក ការតំកល់ នឹងការចុះបញ្ជី |
| មាត្រា៣១ | ការចូលជាធរមាន ការអនុវត្ត និងការបញ្ចប់ |
| មាត្រា៣២ | កន្លែងតំកល់ទុកសន្ធិសញ្ញា |

# សន្ធិសញ្ញា
# ស្តីពី
# ជំនួយផ្នែកច្បាប់ ទៅវិញទៅមក នៅក្នុងរឿងព្រហ្មទណ្ឌ

រដ្ឋាភិបាលនៃបណ្តាប្រទេស : ព្រុយណេ ដារូហ្សាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណៈរដ្ឋឥណ្ឌូណេស៊ី សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណៈរដ្ឋហ្វីលីពីន សាធារណៈរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃ និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម (ដែលចាប់ពីពេលនេះទៅ ហៅជាឯកវចនៈថា "ភាគី" និង ជាពហុវចនៈ "បណ្តាភាគី") :

**មានបំណង** : ដើម្បីកែលំអប្រសិទ្ធភាពរបស់អាជ្ញាធរអនុវត្តច្បាប់ របស់បណ្តាភាគីក្នុងការបង្ការ ទប់ស្កាត់ ការស៊ើបអង្កេត និង ការចោទប្រកាន់លើបណ្តាករណីរឿងតាមរយៈកិច្ចសហប្រតិបត្តិការ និងការផ្តល់ជំនួយ ផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងរឿងព្រហ្មទណ្ឌ បានព្រមព្រៀងដូចតទៅ :

## មាត្រា ១
## វិសាលភាពនៃជំនួយ

១. ដោយយោងទៅតាមសន្ធិសញ្ញានេះ និង អនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ពួកគេរៀងៗខ្លួន បណ្តា ភាគីនឹងផ្តល់នូវវិធានការជំនួយផ្នែកច្បាប់ នៅក្នុងរឿងព្រហ្មទណ្ឌឱ្យគ្នាទៅវិញទៅមក នៅក្នុងទ្រង់ទ្រាយដ៏ធំបំផុតដែលអាចធ្វើបាន ពោលគឺ ក្នុងការស៊ើបអង្កេត ការចោទប្រកាន់ និង នីតិវិធីរឿងក្តីដែលកំពុងកើតមានឡើង ។

២. យោងតាមសន្ធិសញ្ញានេះ ជំនួយដែលត្រូវផ្តល់ទៅវិញទៅមករួមមាន :

ក. ការទទួលយកភស្តុតាង ឬ កំណត់ហេតុដោយស្ម័គ្រចិត្តពីបុគ្គលនានា

ខ. ការរៀបចំឱ្យបុគ្គលផ្តល់ភស្តុតាង ឬ ជួយនៅក្នុងរឿងព្រហ្មទណ្ឌ

គ. ការចាត់ចែងសេវាឯកសារតុលាការ

ឃ. ការអនុវត្តនីការឆែកឆេរ និង ការដកហូត

ង. ការពិនិត្យលើវត្ថុ ទីកន្លែង

ច. ការផ្តល់ឯកសារ របាយការណ៍ច្បាប់ដើម ឬ ច្បាប់ចម្លង វត្ថុតាងដែលពាក់ព័ន្ធ

ឆ. ការកំណត់អត្តសញ្ញាណ ឬ តាមដានទ្រព្យសម្បត្តិដែលទទួលបានមកពីការប្រព្រឹត្តបទល្មើស និង មធ្យោបាយនៃបទល្មើស

ជ. ហាមឃាត់ការលក់ដូរទ្រព្យសម្បត្តិ ឬត្រូវ ផ្អឹបទុកទ្រព្យសម្បត្តិ ដែលទទួលបានមកពីការប្រព្រឹត្តបទល្មើស ដែលអាចត្រូវយកមកវិញ រឹបអូស ឬ ដកហូត ។

ឈ. ការយកមកវិញ ការរឹបអូស ឬ ការដកហូតទ្រព្យសម្បត្តិដែលទទួលបានមកពីការប្រព្រឹត្តបទល្មើស

ញ. រកឃើញ និង កំណត់អត្តសញ្ញាណសាក្សី និង ជនសង្ស័យ និង

ដ. ការផ្តល់ជំនួយផ្សេងៗ ដែលអាចមានការព្រមព្រៀងគ្នា និងស្របទៅនឹងវត្ថុបំណង របស់សន្ធិសញ្ញានេះ និង ច្បាប់របស់ភាគីទទួលសំណើ។

៣. សន្ធិសញ្ញានេះអនុវត្តចំពោះតែការផ្តល់ជំនួយទៅវិញទៅមក នៅក្នុងចំណោមបណ្តាភាគីតែប៉ុណ្ណោះ ។ បណ្តាបញ្ញត្តិនៃសន្ធិសញ្ញានេះ នឹងមិនបង្កើតសិទ្ធិដែលជាចំណែករបស់បុគ្គលឯកជន ដើម្បីទទួលបានបដិសេធ ឬ ផាត់ចោល នូវភស្តុតាង ដើម្បីបង្អាក់ដល់ការអនុវត្តសំណើសុំជំនួយ ។

៤. គោលបំណងនៃការប្រើ ឃ្លា "មធ្យោបាយបទល្មើស" នៅក្នុងសន្ធិសញ្ញានេះ គឺចង់មានន័យថា ទ្រព្យសម្បត្តិដែលគេប្រើជាប់ទាក់ទិននឹងការប្រព្រឹត្តិបទល្មើស ឬ មានតម្លៃសមមូលទៅនឹងទ្រព្យសម្បត្តិនេះ ។

## មាត្រា ២
## ការមិនអនុវត្ត

១. សន្ធិសញ្ញានេះមិនអនុវត្តចំពោះ :

ក. ការចាប់ ឬ ឃុំខ្លួនបុគ្គលណាម្នាក់ក្នុងគោលបំណងដើម្បីធ្វើបត្យាប័នបុគ្គលនោះ

ខ. ការអនុវត្តន៍សាលក្រមព្រហ្មទណ្ឌដែលបានដាក់ចេញនៅក្នុងភាគីម្ចាស់សំណើរ ដោយភាគីទទួលសំណើមិនដល់កំរិតសមល្មមដែលច្បាប់របស់ភាគីទទួលសំណើអនុញ្ញាតឱ្យ ។

គ. ការផ្ទេរបុគ្គលដែលកំពុងជាប់ឃុំខ្លួន ឱ្យមកអនុវត្តសាលក្រមជាប់ពន្ធនាគារ ។

ឃ. ការផ្ទេរនីតិវិធីរឿងក្តី នៅក្នុងរឿងព្រហ្មទណ្ឌ

២. នៅក្នុងសន្ធិសញ្ញានេះពុំបានផ្តល់សិទ្ធិឱ្យភាគីមួយទៅអនុវត្តយុត្តាធិការ និង បំពេញមុខនាទីនៅក្នុងដែនដីរបស់ភាគីម្ខាងទៀតទេ ដែលនេះជាសិទ្ធិផ្តាច់មុខសំរាប់តែអាជ្ញាធររបស់ភាគីម្ខាងទៀតដោយស្របទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន ។

# មាត្រា ៣
## ការកំរិតលើជំនួយ

១. ភាគីទទួលសំណើនឹងបដិសេធន៍ ការសុំជំនួយប្រសិនបើខ្លួនយល់ឃើញថា ៖

ក. សំណើនោះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ឬ ការផ្ដន្ទាទោសបុគ្គលម្នាក់នូវបទល្មើសដែលជា ឬ បើសំអាងលើហេតុផលនៃការលះទេសៈគឺ បទល្មើសដែលបានប្រព្រឹត្តិនោះមានចរឹតជាបទល្មើសនយោបាយ ។

ខ. សំណើនេះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ឬ ការផ្ដន្ទាទោសបុគ្គលម្នាក់ទាក់ទងដល់អំពើមួយ ឬ កំហុសមួយ ដែលប្រសិនបើវាបានកើតឡើង នៅក្នុងភាគីទទួលសំណើវិញនោះ នឹងត្រូវបានចាត់ទុកថាជាបទល្មើសយោធា នៅក្រោមច្បាប់របស់ភាគីទទួលសំណើ ហើយនេះមិនមែនជាបទល្មើសស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌធម្មតារបស់ភាគីទទួលសំណើ ។

គ. មានហេតុផលធំដុំដែលគួរឱ្យជឿបានថា សំណើត្រូវបានធ្វើឡើងសំរាប់គោលបំណងស៊ើបអង្កេត ចោទប្រកាន់ ផ្ដន្ទាទោស ឬ ក៏ផ្ទុយមកវិញ បណ្ដាលឱ្យមានភាពលំអៀងចំពោះបុគ្គលម្នាក់ដោយសារតែ ជាតិសាសន៍ សាសនា ភេទ ដើមកំណើត ជនជាតិ សញ្ជាតិ ឬ ទស្សនៈនយោបាយ ។

ឃ. សំណើនេះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ការផ្ដន្ទាទោស លើបុគ្គលម្នាក់នូវបទល្មើសនៅក្នុងករណីដែលបុគ្គលនោះ ៖

I. ត្រូវបានកាត់ឱ្យជាប់ទោស ត្រូវបានសំរេចឱ្យរួចខ្លួនឬត្រូវបានលើកលែងទោសដោយតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ច នៅក្នុងភាគីម្ចាស់សំណើ ឬ ភាគីទទួលសំណើ ។

II. បានទទួលការផ្ដន្ទាទោស ដែលចែងដោយច្បាប់ របស់ភាគីម្ចាស់សំណើ ឬភាគីទទួលសំណើ

ទាក់ទងនឹងបទល្មើសនោះ ឬ បទល្មើសផ្សេងមួយទៀត ដែលផ្សំឡើង ដោយអំពើ ឬ កំហុសដូចបទល្មើសដែលបានលើកឡើង ពីដំបូង

ង. សំណើនោះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ឬ ការផ្ដន្ទាទោសទៅលើបុគ្គលទាក់ទងទៅនឹងអំពើ ឬ កំហុសដែលប្រសិនបើបានកើតឡើងនៅក្នុង ភាគីទទួលសំណើ នឹងមិនបានចាត់ទុកជាបទល្មើសដែលប្រឆាំងនឹងច្បាប់របស់ភាគីទទួលសំណើ ក្រៅពីនោះ ភាគី

ទទួលសំណើអាចផ្តល់ជំនួយ ដោយសារគ្មានការប្រព្រឹត្តទ្វេរទោស លុះត្រាតែច្បាប់ក្នុងស្រុក របស់ខ្លួនអនុញ្ញាត ។

ច. ការផ្តល់ជំនួយនឹងប៉ះពាល់ដល់ អធិបតេយ្យភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាសារវ័ន្តរបស់ភាគីទទួលការសំណើ ។

ឆ. ភាគីម្ចាស់សំណើមិនអាចធានាបានថា ខ្លួននឹងមានសមត្ថភាពដើម្បីប្រតិបត្តិតាមសំណើនាពេលអនាគត ដែលធ្វើឡើង ដោយភាគីទទួលសំណើ ដើម្បីសុំជំនួយក្នុងរឿងព្រហ្មទណ្ឌមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ ។

ជ. ភាគីម្ចាស់សំណើមិនអាចធានាបានថា នឹងមិនយកវត្ថុដែលខ្លួនបានស្នើសុំនោះទៅប្រើប្រាស់សំរាប់រឿងហេតុក្រៅពីរឿងព្រហ្មទណ្ឌទាក់ទងទៅនឹងសំណើដែលបានធ្វើឡើង ហើយភាគីទទួលសំណើ មិនយល់ព្រមបោះបង់ចោលការអោយធានានេះ ។

ឈ. ភាគីម្ចាស់សំណើមិនអាចធានាក្នុងការប្រគល់ជូនភាគីទទួលសំណើវិញតាមសំណើនូវ របស់ដែលខ្លួនបានទទួល អនុលោមទៅតាមសំណើនៅពេល ដែលបានបញ្ចប់រឿងព្រហ្មទណ្ឌ ដែលទាក់ទងទៅនឹងការធ្វើសំណើនេះ ។

ញ. ការផ្តល់ជំនួយនោះ អាចធ្វើឱ្យប៉ះពាល់ដល់រឿងព្រហ្មទណ្ឌនៅក្នុងភាគីទទួលសំណើ ឬ

ដ. ការផ្តល់ជំនួយនោះតំរូវឱ្យធ្វើជាជំហ៊ាន១ ដែលផ្ទុយនឹងច្បាប់របស់ភាគីទទួលសំណើ

២. ភាគីទទួលសំណើអាចបដិសេធន៍ក្នុងការផ្តល់ជំនួយ ប្រសិនបើខ្លួនយល់ឃើញថា :

ក. ភាគីម្ចាស់សំណើមិនបានប្រតិបត្តិទៅតាមលក្ខខណ្ឌដែលទាក់ទងនឹងសន្ធិសញ្ញានេះ ឬការរៀបចំ ផ្សេងៗដែលទាក់ទងទៅនឹងសំណើនេះ

ខ. ការផ្តល់ជំនួយនោះ នឹង ឬ ទំនងជានឹងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់បុគ្គលណាម្នាក់ដោយមិនចំពោះថា បុគ្គលនោះស្ថិតនៅក្នុង ឬ ក្រៅដែនដីរបស់ភាគីទទួលសំណើ ឬ

គ. ការផ្តល់ជំនួយនោះ នឹងដាក់បន្ទុកហួសប្រមាណទៅលើធនធាន ដែលភាគីទទួលសំណើរមាន។

៣. ជាគោលបំណងរបស់អនុកថាខណ្ឌ ១ (ក) បណ្តាបទល្មើសខាងក្រោមនេះ នឹងមិនត្រូវបានចាត់ទុកជាបទល្មើសមានចរឹតនយោបាយទេ :

ក. បទល្មើសប្រឆាំងនឹងជីវិត ឬ បុគ្គលដែលជាប្រមុខរដ្ឋ ឬសមាជិកក្រុមគ្រួសាររបស់ប្រមុខរដ្ឋផ្ទាល់

ខ. បទល្មើសប្រឆាំងនឹងជីវិត ឬ បុគ្គលដែលជាប្រមុខនៃរដ្ឋាភិបាលថ្នាក់កណ្ដាល ឬ រដ្ឋមន្ត្រីរបស់រដ្ឋាភិបាលថ្នាក់កណ្ដាល ។

គ. បទល្មើសដែលស្ថិតនៅក្នុងវិសាលភាពនៃសន្ធិសញ្ញាអន្តរជាតិ ដែលទាំងភាគីម្ចាស់សំណើ និងភាគីទទួលសំណើ សុទ្ធតែជាភាគីរបស់សន្ធិសញ្ញានោះ ហើយដែលសន្ធិសញ្ញានោះ ដាក់កាតព្វកិច្ចមកលើភាគី (នានា) ដើម្បីធ្វើបត្យាប័ន ឬ ក៏កាត់ទោសជនជាប់ចោទពីបទល្មើសដែលគេបានប្រព្រឹត្ត ។

ឃ. រាល់ការប៉ុនប៉ង ការញុះញង់ ឬ ការសមគំនិតដើម្បីប្រព្រឹត្តនូវបទល្មើសណាមួយដែលបានលើកឡើងនៅក្នុងអនុកថាខណ្ឌ (ក) និង (ខ) ។

៤. ភាគីទទួលសំណើអាចដាក់កំរិតលើការអនុវត្តន៍បញ្ញត្តិណាមួយដែលមានចែងនៅក្រោមកថាខ័ណ្ឌ ៣ ដោយយោងទៅតាមច្បាប់ក្នុងស្រុករបស់ភាគីម្ចាស់សំណើ ដែលមានចែងបញ្ញត្តិប្រហាក់ប្រហែលគ្នាដែរ ឬ យ៉ាងណានោះ ។

៥. នឹងមិនត្រូវបដិសេធការផ្ដល់ជំនួយ ដោយសារតែមូលហេតុការសំងាត់របស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុប្រហាក់ប្រហែល ឬ ដោយហេតុផលថា បទល្មើសនោះក៏ត្រូវបានគេពិចារណាថា មានពាក់ព័ន្ធ ដល់បញ្ហាសារពើពន្ធនោះឡើយ ។

៦. ភាគីទទួលសំណើអាចផ្អាកការប្រតិបត្តិសំណើ ប្រសិនបើការប្រតិបត្តិភ្លាមៗរបស់ខ្លួន នឹងទៅជាការជ្រៀតជ្រែកទៅក្នុងរឿងព្រហ្មទណ្ឌដែលខ្លួនកំពុងតែដំណើរការនៅក្នុងភាគីទទួលសំណើ ។

៧. មុនពេលនឹងបដិសេធន៏សំណើ ឬ ការផ្អាកការប្រតិបត្តិសំណើរបស់ខ្លួន ដោយអនុលោមទៅតាមមាត្រានេះ ភាគីទទួលសំណើ នឹងពិចារណាថាតើខ្លួនអាចផ្ដល់ជំនួយ ដោយ អាស្រ័យលើលក្ខខណ្ឌជាក់ស្ដែងបានដែរឬអត់ ។

៨. ប្រសិនបើភាគីម្ចាស់សំណើ ទទួលយកជំនួយដែលស្ថិតនៅក្រោមលក្ខខណ្ឌ និង ស្ថានភាពដែលគេបានដាក់ក្រោមកថាខ័ណ្ឌ ៧ នោះខ្លួននឹងត្រូវប្រតិបត្តិតាមលក្ខខណ្ឌ និង ស្ថានភាពរបៀបនេះ ។

៩. ប្រសិនបើភាគីទទួលសំណើបដិសេធន៏ ឬ ផ្អាកជំនួយនោះខ្លួនត្រូវផ្ដល់ដំណឹងដល់ភាគី ម្ចាស់សំណើភ្លាមអំពីមូលហេតុនៃការបដិសេធន៏ ឬ ការផ្អាកនោះ ។

១០. អាស្រ័យដោយច្បាប់ក្នុងស្រុករបស់ពួកគេរៀងៗខ្លួន គូភាគីនឹងធ្វើការដោះដូរជំនួយដែលត្រូវផ្ដល់ទាក់ទងទៅ នឹង បទល្មើសសមមូល ដោយមិនគិតដល់ទោសបញ្ញត្តិ ដែលត្រូវអនុវត្តឡើយ ។

## មាត្រា ៤
## ការតែងតាំងអាជ្ញាធរកណ្តាល

១. ភាគីនីមួយៗ ត្រូវតែងតាំងអាជ្ញាធរកណ្តាលមួយដើម្បីធ្វើ និង ទទួលសំណើអនុលោមតាមសន្ធិសញ្ញានេះ ។

២. ការតែងតាំងអាជ្ញាធរកណ្តាល នឹងធ្វើឡើងនៅពេលនៃការដាក់តំកល់លិខិតតុបករណ៍នៃការសុំផ្តល់សច្ចាប័ន ទទួលស្គាល់ អនុម័ត ឬ ចូលជាសមាជិកនៃសន្ធិសញ្ញានេះ ។

៣. ភាគីនីមួយៗ ត្រូវជូនដំណឹងភាគីផ្សេងៗទៀតឱ្យបានរួសរាន់ អំពីការផ្លាស់ប្តូរនៅក្នុងការតែងតាំងអាជ្ញាធរកណ្តាល ។

៤. អាជ្ញាធរកណ្តាល ត្រូវទំនាក់ទំនងគ្នាដោយផ្ទាល់ ក៏ប៉ុន្តែក៏អាចធ្វើការកំណត់ការទំនាក់ទំនងគ្នាតាមប្រព័ន្ធការទូតបានដែរ ប្រសិនបើពួកគេជ្រើសរើសដូច្នេះ ។

## មាត្រា ៥
## ទម្រង់សំណើ

១. រាល់សំណើសុំជំនួយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬ ប្រសិនបើធ្វើទៅបានតាមរយៈមធ្យោបាយដែលអាចផលិតជាឯកសារលាយលក្ខណ៍អក្សរ ក្រោមលក្ខខណ្ឌដែលអនុញ្ញាតឱ្យ ភាគីទទួលសំណើបង្កើតឡើងនូវយថាភាព (ភាពត្រឹមត្រូវតាមច្បាប់) ។ នៅក្នុងស្ថានភាពបន្ទាន់ ហើយប្រសិនបើច្បាប់របស់ភាគី ទទួលសំណើអនុញ្ញាតឱ្យ នោះសំណើអាចធ្វើឡើងដោយផ្ទាល់មាត់បាន ប៉ុន្តែនៅក្នុងករណីរបៀបនេះ សំណើ ត្រូវមានការបញ្ជាក់ជាលាយលក្ខអក្សរ ក្នុងរយៈពេល ០៥ ថ្ងៃ ។

២. អាជ្ញាធរកណ្តាលត្រូវចាត់ចែងក្នុងការបញ្ជូនរាល់សំណើ ឬ ការទំនាក់ទំនងដែលពាក់ព័ន្ធ។ ក្នុងសភាពការណ៍បន្ទាន់ហើយប្រសិនបើច្បាប់របស់ភាគីទទួលសំណើអនុញ្ញាតឱ្យ រាល់សំណើនិងការទំនាក់ទំនងដែលពាក់ព័ន្ធ អាចត្រូវបានបញ្ជូនតាមរយៈអង្គការនគរបាលអន្តរជាតិ (INTERPOL) ឬ អង្គការនគរបាលអាស៊ីអាគ្នេយ៍ (ASEANAPOL) ។.

## មាត្រា ៦
## ខ្លឹមសារសំណើ

១. សំណើសុំជំនួយក្នុងរឿងព្រហ្មទណ្ឌ ត្រូវផ្ទុកនូវពត៌មានដែលភាគីទទួលសំណើត្រូវការ ដើម្បីប្រតិបត្តិសំណើ ដែលរួមមាន :

ក. ឈ្មោះការិយាល័យម្ចាស់សំណើ និងអាជ្ញាធរមានសមត្ថកិច្ច ធ្វើការស៊ើបអង្កេត ឬ នីតិវិធីរឿងក្តីព្រហ្មទណ្ឌ ដែលទាក់ទងនឹងសំណើនោះ ។

ខ. គោលបំណងរបស់សំណើ និង ប្រភេទជំនួយដែលត្រូវស្នើសុំ

គ. ការពិពណ៌នាចរិតនៃរឿងព្រហ្មទណ្ឌ និង ស្ថានភាពបច្ចុប្បន្នរបស់វា និង របាយការណ៍ដែលបង្ហាញពីសេចក្តីសង្ខេបនៃអង្គហេតុ និង អង្គច្បាប់ ដែលពាក់ព័ន្ធ ។

ឃ. ការពិពណ៌នាអំពីបទល្មើសដែលទាក់ទងនឹងសំណើ រួមទាំងទោសបញ្ញត្តិជាអតិបរមា។

ង. ការពិពណ៌នាអំពីអង្គហេតុ ដែលសំអាងថាជាបទល្មើស និង របាយការណ៍ ឬ អត្ថបទច្បាប់ដែលពាក់ព័ន្ធ

ច. ការពិពណ៌នាអំពីអំពើ ឬ កំហុសចាំបាច់ ឬ រឿងហេតុដែលត្រូវចោទប្រកាន់ ឬ ស្នើសុំឱ្យមានការបញ្ជាក់ ។

ឆ. ការពិពណ៌នាអំពីភស្តុតាង ពត៌មាន ឬ ជំនួយផ្សេងៗដែលត្រូវស្នើសុំ ។

ជ. ហេតុផលសំរាប់ និង សេចក្តីពីស្តារ នៃនីតិវិធីពិសេស ឬ តំរូវការដែលភាគីស្នើសុំប្រាថ្នាចង់ឱ្យគេធ្វើតាម ។

ឈ. ការបញ្ជាក់ច្បាស់ពីពេលវេលាកំណត់ដែលគេចង់បានក្នុងការប្រតិបត្តិតាមសំណើ

ញ. តំរូវការពិសេសដើម្បីរក្សាការសំងាត់ និង មូលហេតុនៃការរក្សាការសំងាត់ និង

ដ. ពត៌មាន និង ការធានាផ្សេងៗ ដែលអាចជាតំរូវការចាំបាច់នៅក្រោមច្បាប់របស់ភាគីទទួលសំណើ ឬ ក៏ចាំបាច់សំរាប់ការប្រតិបត្តិសំណើ ឱ្យបានសមស្រប ។

២. អាស្រ័យដោយកំរិតនៃភាពចាំបាច់ រាល់សំណើសុំជំនួយត្រូវផ្ទុកពត៌មានដូចខាងក្រោម :

ក. អត្តសញ្ញាណ សញ្ជាតិ និងទីតាំង របស់បុគ្គល ឬ បណ្តាបុគ្គលដែលជាកម្មវត្ថុនៃការស៊ើបអង្កេត ឬ នីតិវិធីរឿងក្តីព្រហ្មទណ្ឌ

ខ. អត្តសញ្ញាណ និង ទីតាំង បុគ្គលដែលគេចង់ស្វែងរកភស្តុតាង

គ. អត្តសញ្ញាណ និង ទីតាំង របស់បុគ្គលជាមុខសញ្ញា ទំនាក់ទំនងរបស់បុគ្គលនោះ ទៅនឹងនីនីវិធីរឿងក្តីព្រហ្មទណ្ឌ និង របៀបរបបការងារដែលត្រូវធ្វើ ។

ឃ. ពត៌មាន ស្តីពីអត្តសញ្ញាណ និង ទីសំចត របស់បុគ្គលដែលត្រូវតាមរក ។

ង. ការពិពណ៌នាអំពីរបៀប នៃការយក ឬ ការកត់ត្រាសក្ខីភាព និង កំណត់ហេតុ ។

ច. តារាងសំនួរដែលត្រូវសួរបំភ្លឺសាក្សី

ឆ. ការពិពណ៌នាអំពីឯកសារ របាយការណ៍ ឬ វត្ថុតាង ដែលនឹងត្រូវបង្កើតក៏ដូចជាការពិពណ៌នាអំពីបុគ្គលដែលត្រូវសួរបំភ្លឺដើម្បីបង្កើតនូវឯកសារ របាយការណ៍ និង វត្ថុតាង និង ទំរង់ឯកសាររបាយការណ៍ និង វត្ថុតាងដែលត្រូវបង្កើត និង ត្រូវបញ្ជាក់ ។

ជ. ឯកសាររាយការណ៍ទាក់ទងដល់តំរូវការគួរមានវិត្ថានភស្តុតាង ឬ សេចក្តីថ្លែងសម្បថ ឬ បញ្ជាក់ការពិត ។

ឈ. ការពិពណ៌នាអំពីទ្រព្យសម្បត្តិ ទ្រព្យសកម្ម ឬ វត្ថុដែលទាក់ទងនឹងសំណើរ រួមទាំងភិនភាគ និង ទីតាំងរបស់វា និង

ញ. បង្គាប់តុលាការដែលទាក់ទងនឹងជំនួយដែលស្នើសុំ និង កំណត់ហេតុដែលទាក់ទងនឹងវារៈចុងក្រោយ (សេចក្តីបញ្ចប់) របស់បង្គាប់នោះ ។

៣. បណ្តាសំណើ ឯកសារគាំទ្រ និង ការទំនាក់ទំនងផ្សេងៗដែលត្រូវបានធ្វើឡើងដោយអនុលោមទៅតាមសន្ធិសញ្ញានេះ ត្រូវធ្វើជាភាសាអង់គ្លេស ហើយប្រសិនបើចាំបាច់ ត្រូវអមមកជាមួយនូវការបកប្រែជាភាសារបស់ប្រទេសដែលទទួលសំណើ ឬ ភាសាណាផ្សេងមួយទៀត ដែលភាគីទទួលសំណើអាចទទួលយកបាន ។

៤. ប្រសិនបើភាគីទទួលសំណើពិចារណាឃើញថា ពត៌មានដែលផ្ទុកនៅក្នុងសំណើមិនទាន់គ្រប់គ្រាន់ដើម្បី ផ្តល់លទ្ធភាពដល់ការដោះស្រាយសំណើបាន នោះភាគីដែលទទួលសំណើអាចស្នើសុំពត៌មានបន្ថែម ។ ភាគីម្ចាស់សំណើត្រូវផ្តល់ពត៌មានបន្ថែមនេះ នៅពេលដែលភាគីទទួលសំណើពិចារណាឃើញថា មានការចាំបាច់ដើម្បីផ្តល់លទ្ធភាពដល់ការបំពេញ តាមសំណើ ។

## មាត្រា ៧
## ការប្រតិបត្តិសំណើ

១. សំណើសុំជំនួយ នឹងត្រូវអនុវត្តយ៉ាងរួសរាន់ ទៅតាមរបៀប និង ការអនុវត្តន៍ដែលចែងដោយច្បាប់របស់ភាគីទទួលសំណើ ។ ភាគីទទួលសំណើ នឹងអនុវត្តសំណើតាមរបៀបដែលបានបញ្ជាក់ជូនដោយភាគីម្ចាស់សំណើ ដោយអនុលោមទៅតាមច្បាប់ និង ការអនុវត្តន៍នៅក្នុងស្រុករបស់ខ្លួន ។

២. ប្រសិនជាត្រូវបានស្នើសុំឱ្យធ្វើដូច្នេះ និង អនុលោមទៅតាមច្បាប់ និង ការអនុវត្តន៍ក្នុងស្រុករបស់ខ្លួន នោះភាគីទទួលសំណើនឹងត្រូវធ្វើរាល់ការងាររៀបចំចាំបាច់សំរាប់ការតំណាងរបស់ភាគីម្ចាស់សំណើនៅក្នុងភាគីទទួលសំណើ នៅក្នុងនីតិវិធីរឿងក្តីព្រហ្មទណ្ឌ ដែលកើតចេញពីការស្នើសុំជំនួយ ហើយបើមិន ដូច្នេះទេ គឺដើម្បីតំណាងឱ្យផលប្រយោជន៍របស់ភាគីម្ចាស់សំណើ។

៣. ភាគីទទួលសំណើត្រូវឆ្លើយតបឱ្យបានឆាប់តាមដែលអាចធ្វើបានទៅនឹងការសាកសួរពតិមានដោយភាគីម្ចាស់សំណើ ស្តីអំពីការរីកចំរើនក្នុងការអនុវត្តន៍សំណើ ។

៤. ភាគីទទួលសំណើ អាចសុំឱ្យភាគីម្ចាស់សំណើផ្តល់ពតិមាននៅក្នុងទម្រង់របៀបនេះ ដែលអាចជាការចាំបាច់ដើម្បីផ្តល់លទ្ធភាពឱ្យខ្លួន ក្នុងការអនុវត្តន៍សំណើ ឬ ក៏អនុវត្តវិធានការនានាដែលអាចមានភាពចាំបាច់នៅក្រោមច្បាប់ និង ការអនុវត្តន៍របស់ភាគីទទួលសំណើដើម្បីផ្តល់ប្រសិទ្ធិភាពដល់សំណើរដែលទទួលពីភាគីម្ចាស់សំណើ ។

## មាត្រា ៨

## ការកំរិតលើការប្រើប្រាស់ភស្តុតាងដែលទទួលបាន

១. គ្មានការយល់ព្រមពីភាគីទទួលសំណើ និង អនុលោមទៅតាម លក្ខខណ្ឌដូចដែល ភាគីទទួលសំណើពិចារណាឃើញថាចាំបាច់ គឺភាគីម្ចាស់សំណើមិនត្រូវប្រើប្រាស់ ឬ បញ្ចេញ ឬ ផ្ទេរ ពតិមាន ឬ ភស្តុតាងដែលផ្តល់ដោយភាគីទទួលសំណើ សំរាប់គោលបំណងនានាក្រៅពីគោលបំណង ដែលបានលើកឡើងនៅក្នុងសំណើ ។

២. បើទោះជាមានចែងនៅក្នុងកថាខ័ណ្ឌ១ក្តី បើមានការកែប្រែបទចោទប្រកាន់នៅក្នុងករណីរឿងនោះ ពតិមាន ឬ ភស្តុតាងដែលបានផ្តល់ អាចយកមកប្រើត្រឹមតែបទល្មើសដូចដែលបានចោទ ដោយមានការព្រមព្រៀងជាមុនពីភាគីទទួលសំណើ នោះគឺជាបទល្មើសទាក់ទងដល់ការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកក្រោមសន្ធិសញ្ញា ហើយដែលបានធ្វើឡើងដោយផ្អែកលើអង្គហេតុដែលនាំឱ្យមានការធ្វើសំណើនេះ ។

## មាត្រា ៩

## ការរក្សាការសំងាត់

១. ដោយអនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើ និង ចាត់វាលវិធានការ សមស្របនានា ដើម្បីរក្សាការសំងាត់ចំពោះសំណើសុំជំនួយ ខ្លឹមសារសំណើព្រមទាំងឯកសារគាំទ្រ សំណើ ហេតុការណ៍នៃការផ្តល់ជំនួយនេះ នឹងការចាត់វិធានការ អនុលោមទៅតាមសំណើ ។ ប្រសិនបើសំណើមិន អាចអនុវត្តបាន ដោយសារតែការមិនបំពានលើតំរូវការរក្សាការសំងាត់ ភាគីទទួលសំណើត្រូវជូនដំណឹងឱ្យភាគីម្ចាស់សំណើជ្រាបពីបញ្ហានេះ ដែលបន្ទាប់មក ត្រូវកំណត់ថាតើគួរអនុវត្ត សំណើ ឬ យ៉ាងណានោះ បើទោះបីជាយ៉ាងដូច្នេះក្តី ។

២.	អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីម្ចាស់សំណើត្រូវចាត់រាល់បណ្តាវិធានការសមស្រប ដើម្បី :

ក.	រក្សាការសំងាត់នូវពត៌មាន និង ភស្តុតាងដែលផ្តល់ឱ្យ ដោយភាគីទទួលសំណើលើកលែងតែគេចាំបាច់ដល់ភស្តុតាង និង ពត៌មាននោះសំរាប់គោលបំណងដែលបានរៀបរាប់នៅក្នុងសំណើ និង

ខ.	ធានាថា ពត៌មាន និង ភស្តុតាងត្រូវបានការពារមិនឱ្យបាត់បង់ និងការបើកមើល ការប្រើប្រាស់ ការកែប្រែ ការបញ្ចេញ ឬ ការប្រើប្រាស់មិនត្រឹមត្រូវផ្សេងៗដែលពុំមានការអនុញ្ញាត ។

## មាត្រា ១០

## ការទទួលយកកំណត់ហេតុដោយស្ម័គ្រចិត្ត

នៅពេលដែលមានសំណើដើម្បីទទួលយកកំណត់ហេតុពីបុគ្គលម្នាក់សំរាប់គោលបំណង នៃរឿងព្រហ្មទណ្ឌ នៅក្នុងភាគីម្ចាស់សំណើ នោះភាគីទទួលសំណើដោយមានការយល់ព្រមពីបុគ្គលនោះ ត្រូវខំខ្នះខ្នែងដើម្បី ទទួលយកកំណត់ហេតុនោះ ។

## មាត្រា ១១

## ការទទួលយកភស្តុតាង

១.	យោងទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើ ត្រូវរៀបចំទទួលយកភស្តុតាង ព្រមទាំងសក្ខីភាព ឯកសារ ឬ របាយការណ៍ដែលមានសម្បថ ឬ បញ្ជាក់ការពិត ពីសាក្សីដើម្បីបញ្ជូនទៅឱ្យភាគីម្ចាស់សំណើសំរាប់គោលបំណងនៃរឿងព្រហ្មទណ្ឌ ។

២.	នៅពេលដែលទទួលយកសក្ខីភាពដែលមានសម្បថ ឬ បញ្ជាក់ការពិតនៅក្រោមមាត្រានេះ បណ្តាភាគីដែលពាក់ព័ន្ធនឹងនីតិវិធីរឿងក្តីព្រហ្មទណ្ឌ នៅក្នុងភាគីម្ចាស់សំណើ ឬ តំណាងស្របច្បាប់របស់គេ អាចចូលខ្លួនមកចោទសួរ បុគ្គលដែលផ្តល់ភស្តុតាងនោះ ដោយអនុលោមទៅតាមច្បាប់ ក្នុងស្រុករបស់ភាគីទទួលសំណើ ។

៣.	នៅក្នុងមាត្រានេះ មិនបានរារាំងការប្រើប្រាស់ ការតភ្ជាប់វីដេអូ ឬ ទូរទស្សន៍ ដែលបញ្ចាំងផ្ទាល់ ឬ ឧបករណ៍សំរួលដល់ការប្រាស្រ័យទាក់ទង សមស្របដទៃទៀត ដោយអនុលោមតាមច្បាប់ និង ការអនុវត្តរបស់ភាគីទទួលសំណើ ក្នុងគោលបំណងអនុវត្តមាត្រានេះ ប្រសិនបើធ្វើដូច្នេះ មានប្រសិទ្ធភាពបំរើ ដល់ផលប្រយោជន៍យុត្តិធម៌ ។

## មាត្រា ១២

## សិទ្ធិ បដិសេធន៍ក្នុងការផ្តល់ភស្តុតាង

១. នៅក្រោមមាត្រា ១១ នៃសន្ធិសញ្ញានេះ បុគ្គលដែលគេតំរូវឱ្យផ្តល់សក្ខីភាព ឬ បង្កើតឯកសារ ឬ របាយការណ៍ ឬ ភស្តុតាងផ្សេងៗ ដែលមានសម្បថ ឬ បញ្ជាក់ការពិត នៅក្នុងភាគីទទួលសំណើ ដោយអនុលោមទៅតាមសំណើសុំជំនួយ គេអាចបដិសេធន៍ក្នុងការផ្តល់នៅពេលដែល :

ក. ច្បាប់របស់ភាគីម្ចាស់សំណើ អនុញ្ញាត ឬ តំរូវឱ្យបុគ្គលនោះ បដិសេធន៍ក្នុងការធ្វើយ៉ាងដូច្នេះ នៅក្នុងកាលៈទេសៈដូចគ្នានេះនៅក្នុងនីតិវិធីរឿងក្តីដែលផ្តើមឡើងនៅក្នុងភាគីទទួលសំណើ ឬ

ខ. ច្បាប់របស់ភាគីម្ចាស់សំណើអនុញ្ញាត ឬ តំរូវឱ្យបុគ្គលនោះ បដិសេធក្នុងការធ្វើដូច្នេះ នៅក្នុងការលៈទេសៈ ដូចគ្នានេះនៅក្នុងនីតិវិធីរឿងក្តីដែលផ្តើមឡើងនៅក្នុងភាគីម្ចាស់សំណើ ។

២. ប្រសិនបើបុគ្គលនោះ អះអាងថា មានសិទ្ធិបដិសេធន៍ក្នុងការផ្តល់សក្ខីភាព ឬ បង្កើតឯកសារ របាយការណ៍ ឬ ភស្តុតាងផ្សេងៗ ដែលមានសម្បថ ឬ បញ្ជាក់ការពិត ក្រោមមាត្រា ១១ នៃសន្ធិសញ្ញានេះ នៅក្រោមច្បាប់របស់ភាគីម្ចាស់សំណើហើយ ប្រសិនបើមានសំណូមពរនោះ ភាគីម្ចាស់សំណើត្រូវផ្តល់លិខិត បញ្ជាក់ស្តីអំពីអត្ថិភាព នៃសិទ្ធិនោះ ឬ ក៏តាមរបៀបផ្សេងដល់ភាគីទទួលសំណើរ ។

## មាត្រា ១៣

## ការផ្តល់ឯកសារ និង របាយការណ៍ផ្សេងៗដែលមានជាសាធារណៈ (ចំហ)

១. ភាគីទទួលសំណើត្រូវផ្តល់ឱ្យភាគីម្ចាស់សំណើនូវច្បាប់ចំលងនៃឯកសារ ឬ របាយការណ៍ចំហ ដែលស្ថិតជាកម្មសិទ្ធិ របស់ក្រសួង និង ស្ថាប័នរដ្ឋាភិបាល ។

២. អនុលោមតាមច្បាប់ និង ការអនុវត្តក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើអាចផ្តល់ឱ្យភាគីម្ចាស់សំណើនូវច្បាប់ចំលងនៃឯកសារ ឬ របាយការណ៍នានា ដែលជាកម្មសិទ្ធិរបស់ក្រសួង និង ស្ថាប័នរដ្ឋាភិបាល ដែលមិនអាចមានជាសាធារណៈ ។ ភាគីទទួលសំណើ អាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីបដិសេធន៍ទាំងស្រុង ឬ ដោយអន្លើ ចំពោះសំណើ ដោយអនុលោមតាមកថាខ័ណ្ឌនេះ ។

## មាត្រា ១៤

## ការចូលរួមរបស់បុគ្គលនៅក្នុងភាគីម្ចាស់សំណើ

១. អនុលោមទៅតាមច្បាប់ និង ការអនុវត្តន៍នៅក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើអាចជួយក្នុងការរៀបចំ សំរាប់បុគ្គលដែលនៅក្នុងភាគីទទួលសំណើ ដោយអនុលោមទៅតាមការព្រមព្រៀង របស់បុគ្គលនោះ ដើម្បីទៅចូលរួមនៅក្នុងភាគីម្ចាស់សំណើ :

ក. ដើម្បីជួយក្នុងការស៊ើបអង្កេត ទាក់ទងនឹងរឿងព្រហ្មទណ្ឌ នៅក្នុងភាគីម្ចាស់សំណើ ឬ

ខ. ដើម្បីចូលខ្លួនក្នុងដំណើការរឿងក្តី ទាក់ទងនឹងរឿងព្រហ្មទណ្ឌនៅក្នុងភាគីម្ចាស់សំណើតែក្នុងករណី ដែលបុគ្គលនោះ ជាបុគ្គល ដែលត្រូវបានចោទប្រកាន់ ។

២. ប្រសិនបើពេញចិត្តនឹងការរៀបចំសំរាប់សុវត្ថិភាពរបស់បុគ្គលនោះ ដែលនឹងត្រូវធ្វើឡើងដោយភាគីម្ចាស់សំណើនោះភាគីទទួលសំណើ ត្រូវកោះអញ្ជើញបុគ្គល ឱ្យចូលមកឱ្យ ឬ ផ្តល់ភស្តុតាង ឬ ជំនួយទាក់ទងដល់រឿងព្រហ្មទណ្ឌនៅក្នុងភាគីម្ចាស់សំណើ ។ គេនឹងជូនដំណឹងឱ្យបុគ្គលនោះបានដឹងអំពីសោហ៊ុយចំណាយ ឬ ប្រាក់ឧបត្ថម្ភដែលខ្លួនត្រូវទទួល ។

៣. ប្រសិនបើបុគ្គលនោះយល់ព្រម ភាគីទទួលសំណើត្រូវជូនដំណឹងភ្លាមដល់ភាគីម្ចាស់សំណើនូវការឆ្លើយតបរបស់បុគ្គលនោះ ព្រមទាំងចាត់វិធានការចាំបាច់នានាដើម្បីបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់បុគ្គលនោះនៅក្នុងភាគីម្ចាស់សំណើ ។

៤. នៅក្នុងមាត្រានេះគ្មានការរារាំង ដល់ការប្រើប្រាស់ ការតភ្ជាប់វីដេអូ ឬ ទូរទស្សន៍ ដែលបញ្ចាំងដោយផ្ទាល់ ឬ ឧបករណ៍សំរួលដល់ការប្រាស្រ័យទាក់ទងសមស្របដទៃទៀត យោង ទៅតាមច្បាប់ និង ការអនុវត្តន៍របស់ភាគីទទួលសំណើ ប្រសិនបើធ្វើដូច្នេះ មានប្រសិទ្ធភាពបំរើដល់ផលប្រយោជន៍យុត្តិធម៌ ។

## មាត្រា ១៥

## ការចូលរួមរបស់បុគ្គលដែលស្ថិតក្នុងការឃុំខ្លួននៅក្នុងភាគីម្ចាស់សំណើ

១. អនុលោមតាមច្បាប់ក្នុងស្រុក និង ការអនុវត្តន៍របស់ខ្លួន ភាគីទទួលសំណើអាចយល់ព្រមអនុញ្ញាតឱ្យបុគ្គលដែលស្ថិតក្រោមការឃុំខ្លួននៅក្នុងភាគីទទួលសំណើ ដោយមានការឯកភាពពីបុគ្គលនោះ ផ្ទេរជាបណ្តោះ អាសន្នទៅឱ្យភាគីម្ចាស់សំណើដើម្បីផ្តល់ភស្តុតាង ឬ ជួយនៅក្នុងការស៊ើបអង្កេត ។

២. ក្នុងខណៈដែលច្បាប់របស់ភាគីទទួលសំណើតំរូវឱ្យឃុំខ្លួនបុគ្គលដែលបានផ្ទេរ ភាគីម្ចាស់សំណើត្រូវឃុំខ្លួនបុគ្គលនោះ ហើយត្រូវបញ្ជូនបុគ្គលដែលត្រូវឃុំខ្លួននោះមកឱ្យភាគីទទួលសំណើវិញនៅពេលបញ្ចប់

រឿងហេតុទាក់ទងនឹងការស្នើសុំផ្ទេរ ឬ ក៏បញ្ជូនត្រឡប់មកមុនពេលដោយហេតុថាវត្តមានរបស់បុគ្គលនោះលែងចាំបាច់ទៀតហើយ ។

៣. នៅពេលដែលភាគីទទួលសំណើ ជូនដំណឹងដល់ភាគីម្ចាស់សំណើ ថា ការឃុំខ្លួនបុគ្គលដែលបានផ្ទេរនោះលែងចាំបាច់តទៅទៀតហើយ បុគ្គលនោះនឹងត្រូវបានដោះលែងពីការឃុំខ្លួន ហើយត្រូវទទួលបានការប្រព្រឹត្តិចំពោះខ្លួនដូចបុគ្គលដែលគេបាននិយាយយោងដល់នៅក្នុងមាត្រា ១៤ នៃសន្ធិសញ្ញានេះ ។

៤. ភាគីម្ចាស់សំណើ នឹងមិនតំរូវឱ្យភាគីទទួលសំណើផ្តួចផ្តើមនីតិវិធីបត្យាប័ន សំរាប់ការបញ្ជូនបុគ្គលដែលបានផ្ទេរនោះត្រឡប់មកវិញឡើយ ។

៥. រយៈពេលដែលបុគ្គលនេះស្ថិតក្រោមការឃុំខ្លួនរបស់ភាគីម្ចាស់សំណើនឹងត្រូវរាប់បញ្ចូលទៅក្នុង រយៈពេលនៃការជាប់ពន្ធនាគារ ឬ ឃុំឃាំងនៅក្នុងភាគីទទួលសំណើ ។

៦. ការផ្ទេរក្រោមមាត្រានេះ និងមិនអាចប្រព្រឹត្តទៅបានទេ បើគ្មានការធានារ៉ាប់រងពីភាគីម្ចាស់សំណើថា :

ក. ចេញ និង ទទួលខុសត្រូវលើសោហ៊ុយចាយវាយសព្វសារពើក្នុងការផ្ទេរការឃុំខ្លួន ។

ខ. រក្សាបុគ្គលនោះនៅក្រោមការឃុំខ្លួនស្របច្បាប់រហូតចប់ដំណើការផ្ទេរការឃុំខ្លួន និង

គ. នៅពេលដែលឈប់ត្រូវការហើយត្រូវបញ្ជូនបុគ្គលនោះឱ្យមកស្ថិតនៅក្រោមការឃុំខ្លួន របស់ភាគីទទួលសំណើវិញភ្លាម បន្ទាប់ពីគេបានមានវត្តមាននៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ឬ តុលាការរបស់ភាគីម្ចាស់សំណើ ។

៧. នៅក្នុងមាត្រានេះ មិនបានរារាំង ការប្រើប្រាស់ការ តភ្ជាប់វីដេអូ ឬ ទូរទស្សន៍ ដែលបញ្ចាំងផ្ទាល់ ឬ ឧបករណ៏សំរួលដល់ការប្រាស្រ័យទាក់ទងសមស្របដទៃទៀត អនុលោមទៅតាមច្បាប់ និង ការអនុវត្តន៏ របស់ភាគីទទួលសំណើ ប្រសិនបើធ្វើដូច្នេះ មានប្រសិទ្ធភាពបំរើដល់ផលប្រយោជន៏យុត្តិធម៌ ។

## មាត្រា ១៦
## លិខិតបើកផ្លូវ

១. យោងតាមកថាខ័ណ្ឌ ២ នៅពេលដែលបុគ្គលម្នាក់មានវត្តមាននៅក្នុងភាគីម្ចាស់សំណើ អនុលោមទៅតាមសំណើដែលបានធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥ នៃសិទ្ធិសញ្ញានេះ :

ក. បុគ្គលនោះនឹងមិនត្រូវបានឃុំខ្លួន ចោទប្រកាន់ផ្តន្ទាទោស ឬ ទទួលរងនូវការដាក់កំហិតផ្សេងៗលើសេរីភាព បុគ្គលនៅក្នុងភាគីម្ចាស់សំណើ ទាក់ទងទៅនឹងអំពើ ឬ កំហុសនានា ឬ ការកាត់

ទោសពីបទល្មើសដែលប្រឆាំងនឹងច្បាប់ របស់ភាគីម្ចាស់សំណើព្រោះតែត្រូវបានចោទថាបានប្រព្រឹត្ត មុនពេលនៃការចេញដំណើររបស់បុគ្គលពីភាគីទទួលសំណើ

ខ. បើគ្មានការយល់ព្រមពីសាមីខ្លួនគេ គឺបុគ្គលនោះក៏មិនតម្រូវឱ្យផ្តល់ភស្តុតាងនៅក្នុងរឿងព្រហ្មទណ្ឌ នៅក្នុងភាគីម្ចាស់សំណើក្រៅ តែពីរឿងព្រហ្មទណ្ឌដែលទាក់ទងនឹងសំណើ ឬ

គ. បុគ្គលនោះមិនត្រូវទទួលរងនូវបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងអំពើ ឬ កំហុស ដែលបុគ្គលនោះត្រូវបានចោទថាបានប្រព្រឹត្តនៅមុនពេលដែលបុគ្គលនោះ ចេញដំណើរពីភាគីទទួលសំណើ ។

២. នឹងឈប់អនុវត្តកថាខ័ណ្ឌ ១ ប្រសិនបើបុគ្គលនោះមានសេរីភាព អាចចាកចេញបាន ប៉ុន្តែមិនទាន់បានចាកចេញពីភាគីម្ចាស់សំណើ ក្នុងរយៈពេល ១៥ ថ្ងៃជាប់ៗគ្នា បន្ទាប់ពីបុគ្គលនោះត្រូវបានប្រាប់ ឬជូនដំណឹងជាផ្លូវការ ថា : វត្តមានរបស់គេលែងចាំបាច់ទៀតហើយ ឬមួយក៏បានចាកចេញហើយ តែបានវិលត្រឡប់មកវិញដោយស្ម័គ្រចិត្ត ។

៣. បុគ្គលដែលមកចូលរួមនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ឬ តុលាការនៅក្នុងភាគីម្ចាស់សំណើ ដោយយោងតាមសំណើដែលបានធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥ នៃសន្ធិសញ្ញានេះ នឹងមិនត្រូវរងនូវការចោទប្រកាន់ ដោយសំអាងលើសក្ខីភាពដូច្នេះទេ ដោយលើកលែងតែបុគ្គលនោះត្រូវស្ថិតនៅក្រោមច្បាប់របស់ភាគីម្ចាស់សំណើទាក់ទងនឹងការមិនស្តាប់បង្គាប់តុលាការ និងផ្តល់សក្ខីភាពទុច្ចរិត ។

៤. បុគ្គលដែលមិនយល់ព្រមមកចូលរួមនៅក្នុងភាគីម្ចាស់សំណើ យោងតាមសំណើដែលបានធ្វើឡើងនៅក្រោមមាត្រា ១៤ ឬ ១៥ នៃសន្ធិសញ្ញានេះ នឹងមិនត្រូវទទួលទោស ឬ ទទួលខុសត្រូវដោយគ្រាន់តែផ្អែកលើមូលហេតុការបដិសេធ ឬ ខកខានមិនបានយល់ព្រមនោះទេ ឬ បើទោះជាផ្ទុយមកវិញ ធ្វើឱ្យខូច ប្រយោជន៍នៅក្នុងច្បាប់ ផ្ទុយទៅនឹងសំណើក៏ដោយ ។

## មាត្រា ១៧
## ការបញ្ជូនមនុស្សកំពុងស្ថិតក្នុងការឃុំខ្លួន

១. យោងតាមច្បាប់ និងការអនុវត្តន៍នៅក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើអាចអនុញ្ញាតិអោយភាគីម្ចាស់សំណើឬប្រទេសទីបី បញ្ជូនបុគ្គលដែលកំពុងស្ថិតក្នុងការឃុំខ្លួនឆ្លងកាត់ទឹកដី របស់ខ្លួនតាមការស្នើសុំរបស់ភាគីម្ចាស់សំណើ ដើម្បីមកបង្ហាញដោយផ្ទាល់នៅក្នុងរឿងព្រហ្មទណ្ឌ ។

២. នៅពេលដែលយន្តហោះ នាវា ឬរថភ្លើង ដែលដឹកនាំបុគ្គលនោះ ចូលចត ឬឈប់នៅក្នុងភាគីទទួលសំណើ នោះមន្ត្រីដែលគ្រប់គ្រង ឬហែរហមរបស់ភាគីម្ចាស់សំណើ ឬបើអាចអនុវត្តទៅបាន ប្រទេស

ទីបីដែលកំពុងជួយភាគីម្ចាស់សំណើ ដើម្បីបង្កភាពងាយស្រួលដល់ការផ្ទេរនោះ នឹងបន្តទទួលខុសត្រូវលើ ការឃុំខ្លួនបុគ្គលដែលខ្លួនកំពុងដឹកនាំ ហើយដែលកំពុងតែធ្វើដំណើរឆ្លងកាត់នៅក្នុងភាគីទទួលសំណើ ដរាបណាមានការព្រមព្រៀងផ្ទុយពីនេះដោយភាគីទទួលសំណើ ។

៣. ដោយមិនធ្វើអោយប៉ះពាល់ដល់កថាខ័ណ្ឌ ២ និងដោយមានការយល់ព្រមពីភាគីទទួលសំណើបុគ្គលដែលគេកំពុងដឹកនាំអាចត្រូវរក្សាទុក នៅក្រោមការឃុំខ្លួនរបស់អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួល សំណើរហូតដល់ការដឹកជញ្ជូននេះចាប់បន្តដំណើរទៀត ។

៤. នៅពេលដែលបុគ្គលដែលកំពុងស្ថិតក្រោម ការឃុំខ្លួននៅក្នុងភាគីទទួលសំណើកំពុងតែធ្វើដំណើរឆ្លងកាត់ ហើយ ការដឹកនាំបុគ្គលនោះ មិនបានធ្វើបន្តនៅក្នុងពេលវេលាសមហេតុផលនោះ ភាគីទទួលសំណើអាច បង្គាប់អោយដឹកនាំបុគ្គលនោះយកទៅឃុំខ្លួននៅក្នុងរដ្ឋទីមួយដែលគេដឹកនាំ បុគ្គលនោះចេញមក ។

៥. រាល់ការចេញចំណាយនឹងសោហ៊ុយ ដោយរដ្ឋទទួលសំណើទាក់ទងនឹងកថាខ័ណ្ឌ ៣ និងទី ៤ នឹងត្រូវបានភាគីម្ចាស់សំណើចេញសងវិញ ។

## មាត្រា ១៨
## ការឆែកឆេរ និងការដកហូត

១. អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើ ត្រូវអនុវត្តសំណើសុំឆែកឆេរ ដកហូត និងប្រគល់ឯកសារ របាយការណ៍ ឬសំភារៈ អោយទៅភាគីម្ចាស់សំណើ ប្រសិនបើមានហេតុផលសមរម្យដើម្បីជឿថាឯកសារ របាយការណ៍ ឬសំភារៈទាំងនោះមានជាប់ពាក់ព័ន្ធនឹងរឿងព្រហ្មទណ្ឌ នៅក្នុងភាគីម្ចាស់សំណើ ។

២. ភាគីម្ចាស់សំណើត្រូវគោរពទៅតាមលក្ខខណ្ឌដែលភាគីទទួលសំណើបានដាក់ ទាក់ទងទៅនឹងឯកសាររបាយការណ៍ ឬសំភារៈដែលបានដកហូត អាចត្រូវប្រគល់ជូនភាគីម្ចាស់សំណើ ហើយដែលភាគីទទួលសំណើយល់ឃើញថាចាំបាច់ដើម្បីការពារឯកសារ របាយការណ៍ ឬសំភារៈដែលបានផ្ទេរទាំងនោះ ។

៣. ភាគីទទួលសំណើត្រូវជូនដំណឹងទៅភាគីម្ចាស់សំណើអោយបានឆាប់តាមដែលអាចធ្វើទៅបាន នូវលទ្ធផលនៃការឆែកឆេរ ទីកន្លែង និងកាលៈទេសៈ នៃការដកហូត និងការឃុំគ្រងឯកសារ របាយការណ៍ និងសំភារៈដែលបានដកហូតជាបន្តបន្ទាប់មក ។

## មាត្រា ១៩
## ការបញ្ជូនវត្ថុតាងត្រឡប់ទៅវិញ

១. នៅពេលបញ្ចប់រឿងព្រហ្មទណ្ឌដែលទាក់ទងដល់ការធ្វើសំណើសុំជំនួយ ភាគីម្ចាស់សំណើត្រូវបញ្ជូនត្រឡប់ទៅអោយភាគីទទួលសំណើវិញ នូវឯកសារ របាយការណ៍ ឬសំភារៈដែលបានផ្តល់ជូនភាគីម្ចាស់សំណើយោងតាមសំណើ ក្រោមសន្ធិសញ្ញានេះ ។

២. បើទោះជាមានចែងនៅក្នុងកថាខ័ណ្ឌ ១ ក្តី ភាគីម្ចាស់សំណើនៅពេលបានទទួលសំណើទោះជានៅពេលណាក៏ដោយ ត្រូវបញ្ជូនត្រឡប់មកអោយភាគីទទួលសំណើវិញជាបណ្តោះអាសន្ននូវឯកសារ របាយការណ៍ ឬ សំភារៈដែលបានផ្តល់ជូនភាគីម្ចាស់សំណើយោងតាមសំណើនៅក្រោមសិន្ធិសញ្ញានេះ ប្រសិនបើភាគីទទួលសំណើរត្រូវការចាំបាច់ឯកសារ របាយការណ៍ ឬ សំភារៈទាំងនេះនៅក្នុងរឿងព្រហ្មទណ្ឌរបស់ខ្លួន ។

## មាត្រា ២០
## ទីតាំង ឬ អត្តសញ្ញាណរបស់បុគ្គល

១. យោងតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើត្រូវប្រើប្រាស់អោយអស់នូវកិច្ចខិតខំខ្នះខ្នែងរបស់ខ្លួន ដើម្បីបញ្ជាក់អោយច្បាស់ពីទីកន្លែង ឬ អត្តសញ្ញាណរបស់បុគ្គលដូចបានបញ្ជាក់ជូនក្នុងសំណើ ហើយដែលត្រូវបានគេជឿដោយសមហេតុសមផលថា កំពុងស្ថិតនៅក្នុងទឹកដីរបស់ខ្លួន ។

## មាត្រា ២១
## សេវាឯកសារ

១. អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើត្រូវប្រើប្រាស់អោយអស់កិច្ចខិតខំខ្នះខ្នែងរបស់ខ្លួន ដើម្បីអនុវត្តសេវាឯកសារ ដែលចេញដោយតុលាការ នៅក្នុងភាគីម្ចាស់សំណើទាក់ទងនឹងរឿងព្រហ្មទ័ណ្ឌ។

២. ភាគីម្ចាស់សំណើត្រូវបញ្ជូនសំណើសំរាប់សេវាឯកសារដែលតំរូវ អោយមានការឆ្លើយតប ឬ ការបង្ហាញខ្លួននៅក្នុងភាគីម្ចាស់សំណើ មិនអោយតិចជាង ៣០ថ្ងៃ មុនកាលកំណត់ត្រូវឆ្លើយតប ឬការបង្ហាញខ្លួន ។

៣. ភាគីទទួលសំណើត្រូវបញ្ជូនត្រឡប់នូវតឹកតាងសេវាទៅតាមរបៀបដែលបានព្រមព្រៀងគ្នាទៅវិញទៅមកដោយភាគីដែលពាក់ព័ន្ធ ។

៤. សំរាប់គោលបំណងនៃកថាខ័ណ្ឌ ៣ ឃ្លា "តឹកតាងសេវា" រួមមាន ពត៌មានដែលមានទម្រង់ជាលិខិតថ្លែងសច្ចាអំពី ការប្រគល់ជូនឯកសារប្រព្រឹត្តទៅ នៅពេលណា និង យ៉ាងដូចម្ដេច ហើយបើអាចធ្វើទៅបានត្រូវមានបង្កាន់ដៃចុះហត្ថលេខាដោយបុគ្គលដែលគេបានប្រគល់ជូន ហើយប្រសិនបើមន្ត្រី ដែលជាអ្នកប្រគល់ជូននោះមិនមានលទ្ធភាពក្នុងការប្រគល់ជូនឯកសារនោះទេ ត្រូវផ្ដល់នូវដំណើរហេតុ និងមូលហេតុសំរាប់ការខកខាននេះ ។

## មាត្រា ២២

## ជំនួយក្នុងចំណាត់ការរឹបអូស

១. អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើត្រូវខ្នះខ្នែង រកឱ្យឃើញទីតាំង តាមដានរារាំង ផ្អឹបទុក ដកហូត ឬ រឹបអូសទ្រព្យសម្បត្តិដែលបានមកពីការប្រព្រឹត្តបទល្មើស និងជាមធ្យោបាយបទល្មើស ដែលដែលគេអាចផ្ដល់ជំនួយរបៀបនេះជូនបានលុះត្រាតែភាគីម្ចាស់សំណើ ផ្ដល់រាល់ពត៌មាន ដែល ភាគីទទួលសំណើយល់ឃើញថាចាំបាច់ ។

២. នៅពេលដែលសំណើត្រូវបានធ្វើឡើងតាមកថាខ័ណ្ឌ ១ សំណើនោះត្រូវអមមកជាមួយនូវដីកាច្បាប់ដើមដែលមានចុះហត្ថលេខា ឬ ច្បាប់ចំលងដីកាដែលមានបញ្ជាក់ត្រឹមត្រូវ ។

៣. សំណើសុំជំនួយក្រោមមាត្រានេះត្រូវធ្វើឡើងតែទាក់ទងទៅនឹងដីកា ឬ សាលក្រមដែលបានចេញក្រោយពេលដែលសន្ធិសញ្ញានេះបានចូលជាធរមានប៉ុណ្ណោះ ។

៤. យោងតាមច្បាប់ក្នុងស្រុករបស់ភាគីទទួលសំណើ ទ្រព្យសម្បត្តិដែលត្រូវបានដកហូត ឬ រឹបអូសអនុលោមតាមមាត្រានេះ អាចបន្ថែមទៅអោយភាគីម្ចាស់សំណើ ដរាបណាមានការព្រមព្រៀងផ្សេងពីនេះនៅក្នុងករណីពិសេសនីមួយៗ ។

៥. យោងតាមច្បាប់ក្នុងស្រុក និង អនុលោមតាមកិច្ចព្រមព្រៀងជាមួយនឹង ភាគីម្ចាស់សំណើ ភាគីទទួលសំណើត្រូវផ្ទេរទៅអោយ ភាគីម្ចាស់សំណើនូវចំណែកទ្រព្យសម្បត្តិ ដែលបានព្រមព្រៀងជាទ្រព្យសម្បត្តិដែលទទួល បានមកក្រោមមាត្រានេះដើម្បីទូរទាត់ថ្លៃចំណាយ និងសោហ៊ុយ ដែលភាគីទទួលសំណើបានចំណាយ នៅក្នុងការអនុវត្តន៍ដីការឹបអូស ។

## មាត្រា ២៣

## ភាពចុះសម្រុងជាមួយនឹងការរៀបចំផ្សេងៗ

សិទ្ធិសញ្ញានេះមិនរារាំងបណ្ដាភាគីពីការផ្ដល់ជំនួយអោយគ្នាដោយអនុលោមទៅតាមបណ្ដាសន្ធិសញ្ញាការរៀបចំ ឬបណ្ដាបញ្ញត្តិផ្សេងៗ នៃច្បាប់ជាតិរបស់ពួកគេ ។

## មាត្រា ២៤
## វិញ្ញាបនកម្ម និងភស្តុតាងបញ្ជាក់

១. ពេលទទួលបានសំណើ ភាគីនីមួយៗ ត្រូវផ្តល់ការបញ្ជាក់លើឯកសារ ឬ សំភារៈដែលត្រូវបញ្ជូនទៅអោយភាគីផ្សេងៗក្រោមសន្ធិសញ្ញានេះ ។

២. ត្រូវផ្តល់ការបញ្ជាក់អោយបានត្រឹមត្រូវលើឯកសារ ដើម្បីបំពេញគោលបំណង នៃសន្ធិសញ្ញានេះ ប្រសិនបើ :

ក. វាអះអាងថាត្រូវចុះហត្ថលេខា ឬបញ្ជាក់ដោយចៅក្រម ឬមន្ត្រីដែលនៅក្នុង ឬរបស់ភាគីបញ្ជូនឯកសារ ដែលទទួលបានការអនុញ្ញាតិត្រឹមត្រូវពីភាគីនោះ និង

ខ. ទាំង :

(១) ត្រូវផ្ទៀងផ្ទាត់ដោយសម្បថ ឬការបញ្ជាក់អះអាងរបស់សាក្សីឬរបស់មន្ត្រីរដ្ឋាភិបាលនៃភាគីនោះ ឬ

(២) វាអះអាងថាត្រូវបោះត្រា ដោយត្រាផ្លូវការ ឬ របស់រដ្ឋនៃភាគីនោះ ឬ របស់ទេសរដ្ឋមន្ត្រី ឬ របស់ស្ថាប័ន ឬ របស់មន្ត្រីរដ្ឋាភិបាលនៃភាគីនោះ ។

៣. ក្នុងមាត្រានេះមិនបានរារាំង ភស្តុតាងនៃរឿងហេតុ ឬ ការទទួលស្គាល់ភស្តុតាងជាឯកសារស្របទៅតាមច្បាប់របស់ភាគីម្ចាស់សំណើទេ ។

៤. អនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ភាគីនីមួយៈ

ក. ឯកសារដែលចុះហត្ថលេខា ដោយហត្ថលេខាឌីជីថល ឬអេឡិចត្រូនិចស្របទៅតាមច្បាប់របស់ភាគីពាក់ព័ន្ធ ត្រូវតែប្រតិបត្តិទៅតាមផ្លូវច្បាប់ ដូចឯកសារដែលចុះហត្ថលេខាសរសេរដោយដៃ ស្នាមផ្តិតមេដៃ ឬ សញ្ញាសំគាល់ផ្សេងៗទៀត និង

ខ. ហត្ថលេខាឌីជីថល ឬអេឡិចត្រូនិច ដែលត្រូវបានបង្កើតឡើងស្របទៅតាមច្បាប់របស់ភាគីពាក់ព័ន្ធ នឹងត្រូវបានចាត់ទុកថាជាហត្ថលេខា ត្រឹមត្រូវតាមច្បាប់ហើយត្រូវតែប្រតិបត្តិតាម ។

## មាត្រា ២៥
## ថ្លៃចំណាយ

១. ភាគីទទួលសំណើនឹងត្រូវចេញរាល់ការចំណាយធម្មតាក្នុងការបំពេញតាមសំណើសុំជំនួយ លើកលែងតែភាគីម្ចាស់សំណើដែលត្រូវចេញ :

ក. សោហ៊ុយមេធាវី ដែលគេបានជួលតាមសំណើរបស់ភាគីម្ចាស់សំណើ

ខ. សោហ៊ុយនិងថ្លៃចំណាយលើសាក្សីជំនាញ

គ. ថ្លៃចំណាយការបកប្រែ និងការកត់ត្រាជាលាយល័ក្ខអក្សរ (កំណត់ហេតុ)

ឃ. សោហ៊ុយចំណាយទាក់ទងនឹងការដឹកនាំបុគ្គល ទៅ មកពីភាគីទទួលសំណើ និង សោហ៊ុយ ប្រាក់ឧបត្ថម្ភ និងថ្លៃចំណាយបុគ្គលដែលពាក់ព័ន្ធក្នុងខណៈ ដែលបុគ្គលនោះ កំពុងស្ថិតនៅក្នុងភាគីម្ចាស់សំណើ អនុលោមតាមសំណើដែលបានធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥នៃសន្ធិសញ្ញានេះ និង

ង. ចំណាយដែលទាក់ទងដល់មន្ត្រីដឹកនាំ គ្រប់គ្រង ឬអមដំណើរ ។

២. ថ្លៃចំណាយលើការតម្លើង ដើម្បីតភ្ជាប់វីដេអូ ឬទូរទស្សន៍ផ្សាយផ្ទាល់ ឬ ឧបករណ៍សំរួលដល់ការប្រាស្រ័យទាក់ទងសមស្របផ្សេងៗទៀត ថ្លៃចំណាយទាក់ទងនឹងសេវាតភ្ជាប់ វីដេអូឬទូរទស្សន៍បន្តផ្ទាល់ ឬ ឧបករណ៍សំរួលដល់ការប្រាស្រ័យទាក់ទងសមស្របផ្សេងៗទៀត ប្រាក់ឈ្នួលបកប្រែដែលផ្តល់ដោយភាគីទទួលសំណើ និងប្រាក់ឧបត្ថម្ភដល់សាក្សី និងថ្លៃចំណាយការធ្វើដំណើរ របស់គេនៅក្នុងភាគីទទួលសំណើ នឹងត្រូវបានភាគីម្ចាស់សំណើចេញសងអោយភាគីទទួលសំណើវិញ ដរាបណាគូភាគីមានការព្រម ព្រៀងទៅវិញទៅមកផ្ទុយពីនេះ ។

៣. ប្រសិនបើក្នុងអំឡុងពេលនៃការអនុវត្តន៍សំណើបានបង្ហាញច្បាស់ពីតំរូវការចំណាយជាក់ស្តែងដែលមានលក្ខណៈ វិសាមញ្ញ ឬជាដុំកំភួន ដើម្បីបំពេញតាមសំណើ នោះគូភាគីត្រូវពិគ្រោះយោបល់គ្នា ដើម្បីកំណត់ ល័ក្ខខ័ណ្ឌអនុវត្តសំណើជាបន្ត ។

## មាត្រា ២៦

## ការពិគ្រោះយោបល់

១. អាជ្ញាធរកណ្តាលនៃគូភាគី ដោយមានការព្រមព្រៀងគ្នាទៅវិញទៅមករវាងពួកគេ ជូនកាលត្រូវធ្វើការពិគ្រោះយោបល់គ្នាដើម្បីជំរុញការប្រើប្រាស់សន្ធិសញ្ញានេះអោយមានប្រសិទ្ធភាពខ្ពស់បំផុត ។

២. គូភាគីអាចបង្កើតនូវវិធានការអនុវត្តនានាដែលអាចជាការចាំបាច់ដើម្បីជួយសំរួលដល់ការអនុវត្តន៍សន្ធិសញ្ញានេះ ។

## មាត្រា ២៧

## វិសោធនកម្ម

១. សន្ធិសញ្ញានេះ អាចត្រូវបានកែសំរួល ឬធ្វើវិសោធនកម្មនៅពេលណាមួយ តាមរយៈការព្រមព្រៀងជាលាយល័ក្ខអក្សរដោយគូភាគី ។ ការកែសំរួល ឬ វិសោធនកម្មបៀបនេះ នឹងចូលជាធរមាន តាមកាល

បរិច្ឆេទ ដូចដែលគូភាគីអាចមានការព្រមព្រៀងគ្នាទៅវិញទៅមក បន្ទាប់នឹងក្លាយទៅជាផ្នែកមួយ នៃសន្ធិសញ្ញានេះ ។

២. រាល់ការកែសំរួល ឬ វិសោធនកម្ម នឹងមិនប៉ះពាល់ដល់សិទ្ធិ ឬ កាតព្វកិច្ចដែលកើតចេញពី ឬ ដែលផ្អែកលើសន្ធិសញ្ញានេះ នៅមុនពេល ឬ រហូតដល់កាលបរិច្ឆេទ ដែលការកែសំរួលឬវិសោធនកម្មនេះចូលជាធរមាន ។

## មាត្រា ២៨

## ដំណោះស្រាយវិវាទ

រាល់ការខ្វែងគំនិត ឬ វិវាទរវាងគូភាគីដែលកើតចេញពីការបកស្រាយ ឬ ការអនុវត្តន៍បញ្ញត្តិនៃសន្ធិសញ្ញា នឹងត្រូវបានដោះស្រាយប្រកបដោយមេត្រីភាព តាមរយៈនៃការពិគ្រោះយោបល់ ឬ ការចរចារវាងគូភាគី តាមរយៈប្រព័ន្ធការទូត ឬមធ្យោបាយដោយសន្តិវិធីផ្សេងៗសំរាប់ដោះស្រាយវិវាទទៅតាមការព្រមព្រៀងគ្នា របស់គូភាគី ។

## មាត្រា ២៩

## ខរក្សាសិទ្ធិ (ថិបនីយ)

សន្ធិសញ្ញានេះ នឹងមិនស្ថិតនៅក្រោម ខរក្សាសិទ្ធិឡើយ ។

## មាត្រា ៣០

## ហត្ថលេខា សច្ចាប័ន ការចូលជាសមាជិក ការតំកល់ និងការចុះបញ្ជី

១. សន្ធិសញ្ញានេះនឹងតំរូវអោយមានការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការអនុម័ត ឬ ការចូលជាសមាជិកស្របទៅតាមនីតិវិធីស្ថាប័នរបស់បណ្តារដ្ឋហត្ថលេខី ។

២. រដ្ឋណាក៏អាចចូលរួមនៅក្នុងសន្ធិសញ្ញានេះបាន អាស្រ័យដោយមតិទូទៅរបស់បណ្តាភាគីដើម ។

៣. លិខិតុបករណ៍នៃការសុំផ្តល់សច្ចាប័ន ការទទួលស្គាល់ ការអនុម័ត ឬការចូលជាសមាជិកនឹងត្រូវបានដាក់តំកល់នៅរដ្ឋា ភិបាលម៉ាឡេស៊ី ដែលគេបានកំណត់ថា ជារដ្ឋកន្លែងតំកល់ទុក ។

៤. រដ្ឋជាកន្លែងតំកល់ទុកត្រូវជូនដំណឹងដល់បណ្តារដ្ឋផ្សេងៗដែលជាភាគីនៃសន្ធិសញ្ញានេះបានជ្រាបស្តីពីការតំកល់ទុក លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការអនុម័ត ឬ ការចូលជាសមាជិក ។

៥. រដ្ឋកន្លែងតំកល់ទុកត្រូវចុះបញ្ជីសន្ធិសញ្ញានេះ អនុលោមទៅតាមមាត្រា ១០២ របស់ធម្មនុញ្ញសហប្រជាជាតិ ។

## មាត្រា ៣១
## ការចូលជាធរមាន ការអនុវត្តន៍និងការបញ្ចប់

១. សន្ធិសញ្ញានេះនឹងចូលជាធរមានសំរាប់ភាគីនីមួយៗ ផ្តល់សច្ចាប័ន ទទួលស្គាល់ អនុម័ត ឬ ចូលជាសមាជិកទៅតាមកាលបរិច្ឆេទ នៃការតំកល់ លិខិតុបករណ៍នៃការនៃការសុំផ្តល់សច្ចាប័ន ការទទួលស្គាល់ ការអនុម័ត ឬ ការចូលជាសមាជិក។

២. សន្ធិសញ្ញានេះនឹងអនុវត្តចំពោះសំណើដែលបានដាក់ជូនបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់វា សំរាប់ភាគី ដែលពាក់ព័ន្ធទាំងពីរ មិនដោយគិតថាអំពើ ឬកំហុសនានាដែលចាត់ទុកជាបទល្មើសបានកើត ឡើងមុន ឬក្រោយកាលបរិច្ឆេទនោះឡើយ ។

៣. ភាគីណាក៏អាចប្រកាសដកខ្លួនចេញពីសន្ធិសញ្ញានេះបាន តាមរយៈសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរ ជូនចំពោះរដ្ឋដែលជាកន្លែងតំកល់ទុក ។ ការប្រកាស ដកខ្លួននឹងចាប់មានប្រសិទ្ធភាពក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋតំកល់ទុក ទទួលបានសេចក្តីជូនដំណឹងនោះ ។

៤. ការប្រកាសដកខ្លួនពីសន្ធិសញ្ញានេះ នឹងមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចដែលកើតចេញពី ឬផ្អែកលើសន្ធិសញ្ញានេះទេ នៅមុនពេល ឬ រហូតដល់កាលបរិច្ឆេទនៃការប្រកាសដកខ្លួន ។

៥. ការប្រកាសដកខ្លួនពីសន្ធិសញ្ញានេះនឹងមានប្រសិទ្ធិភាព ចំពោះតែភាគីដែលបានជូនដំណឹងប៉ុណ្ណោះ ។ សន្ធិសញ្ញានេះស្ថិតនៅជាធរមាន សំរាប់ភាគីផ្សេងៗទៀត ។

## មាត្រា ៣២
## កន្លែងតំកល់ទុកសន្ធិសញ្ញា

ច្បាប់ដើមនៃសន្ធិសញ្ញានេះនឹងត្រូវតំកល់ទុកនៅឯរដ្ឋដែលជាកន្លែងតំកល់ ដែលរដ្ឋនោះនឹងផ្ញើច្បាប់ចំលង សន្ធិសញ្ញាទៅអោយគ្រប់ភាគីទាំងអស់ ។

ដើម្បីជាសាក្សី នៃសន្ធិសញ្ញានេះ : អ្នកចុះហត្ថលេខាខាងក្រោមនេះ សុទ្ធតែបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីរដ្ឋាភិបាលរៀងៗខ្លួន និងបានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

ធ្វើនៅទីក្រុង គូឡាឡាំពួរ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដែលមានច្បាប់ដើមជាភាសាអង់គ្លេសមួយច្បាប់

| | |
|---|---|
| សំរាប់រដ្ឋាភិបាលព្រុយណេដារូសាឡឹម | សំរាប់រាជរដ្ឋាភិបាលកម្ពុជា |
| ........................................ | ................................ |
| ដាតូ សេរី ប៉ាឌូកា ហាជីគីហ្វ្រីរី ដាតូ ប៉ាឌូកា ហាជីគីហ្វ្រី<br>រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អង្គ វង្សវឌ្ឍនា<br>រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| សំរាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី | សំរាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ |
| .............................. | ..................................... |
| បណ្ឌិត ហាមីដ អាវ៉ាលូឌីន<br>រដ្ឋមន្ត្រីក្រសួងច្បាប់ និងសិទ្ធិមនុស្ស | ខាំ អួន បូផា<br>រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| សំរាប់រដ្ឋាភិបាល ម៉ាឡេស៊ី | សំរាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន |
| .................................................. | ............................................. |
| តាន់ ស្រ៊ីអាប់ឌុលហ្គានីប៉ាតៃ<br>រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ម៉ាកាបាងគីត ឡានតូ<br>អនុរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| សំរាប់រដ្ឋាភិបាលសឹង្ហបុរី | សំរាប់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម |
| .......................................... | ............................................. |
| ចាន់ សិកគ័ង<br>រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ឡេ ថេទាម<br>អនុរដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ |